# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៧៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សាកលវិទ្យាល័យអង្គរ

******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្តលេខ ២១ អនក្រ.បក. ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ. ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និង ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញលិខិតស្នើសុំ របស់លោក សៀង ណាំ ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០០៤
- តាមសំណើររបស់ក្រសួងអប់រំ យុវជន និង កីឡា

## ស ម្រេ ច

**មាត្រា ១ :** ទទួលស្គាល់ គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា សាកលវិទ្យាល័យអង្គរ **"Angkor University"** ហៅកាត់ជាភាសាខ្មែរ ស.អ. និង ហៅកាត់ជាភាសាអង់គ្លេស

A.U. ។ សាកលវិទ្យាល័យនេះ មានទីតាំងស្ថិតនៅ ភូមិខ្នា ឃុំជ្រាវ ស្រុកសៀមរាប ខេត្តសៀមរាប ។

មាត្រា ២ : សាកលវិទ្យាល័យអង្គរ មានតួនាទី ជាមជ្ឈមណ្ឌលបណ្តុះបណ្តាលធនធានមនុស្ស និង ស្រាវជ្រាវ វិប្បធម៌ វិទ្យាសាស្ត្រ បច្ចេកទេស និង ស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៣ : សាកលវិទ្យាល័យអង្គរ ធ្វើការបណ្តុះបណ្តាល :

- ជំនាញរយៈពេលខ្លី
- ថ្នាក់បរិញ្ញាប័ត្ររង សិក្សារយៈពេល ២ ឆ្នាំ ជាមធ្យម
- ថ្នាក់បរិញ្ញាប័ត្រ សិក្សារយៈពេល ៤ ឆ្នាំ ជាមធ្យម
- ថ្នាក់អនុបណ្ឌិត សិក្សារយៈពេល ២ ឆ្នាំ ជាមធ្យម និង
- ថ្នាក់បណ្ឌិត សិក្សាស្រាវជ្រាវ រយៈពេលយ៉ាងតិច ៣ ឆ្នាំ ។

មាត្រា ៤ : សាកលវិទ្យាល័យអង្គរ មានមហាវិទ្យាល័យចំនួនប្រាំ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមួយ

- មហាវិទ្យាល័យមនុស្សសាស្ត្រ និង ភាសាបរទេស
- មហាវិទ្យាល័យវិទ្យាសាស្ត្រ និង បច្ចេកវិទ្យា
- មហាវិទ្យាល័យសង្គមសាស្ត្រ និង នីតិសាស្ត្រ
- មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម និង ទេសចរណ៍
- មហាវិទ្យាល័យកសិកម្ម និង
- មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ។

ទៅអនាគតសាកលវិទ្យាល័យនេះ អាចបើកមហាវិទ្យាល័យ សាខា ឯកទេស ឬប្រភេទអប់រំបណ្តុះបណ្តាលដទៃទៀត ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាត ពីក្រសួងអប់រំ យុវជន និង កីឡា ។

មាត្រា ៥ : សាកលវិទ្យាល័យអង្គរ មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសំរេច លើគោលនយោបាយ ផែនការអភិវឌ្ឍន៍ កម្មវិធីសិក្សា និង ការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត ។

មាត្រា ៦ : តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែង នៃសាកលវិទ្យាល័យអង្គរ ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាល័យនេះ ។

មាត្រា ៧ : សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យអង្គរ មានភារកិច្ច :

- ទទួលខុសត្រូវនៅចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងសាកលវិទ្យាល័យ
- ជ្រើសរើសសិស្ស-និស្សិតអោយចូលរៀន ជ្រើសរើសសាស្ត្រាចារ្យមកបង្រៀន និងបុគ្គលិកបំរើការងារ

- គ្រប់គ្រងអោយបានល្អ នូវការងារបណ្តុះបណ្តាល ការងារស្រាវជ្រាវការប្រលង និងការប្រគល់សញ្ញាប័ត្រ
- គោរព និងអនុវត្តតាមច្បាប់ និងបទដ្ឋាននានា ដែលពាក់ព័ន្ធនឹងការងារបណ្តុះបណ្តាល របស់រាជរដ្ឋាភិបាល និង ក្រសួងអប់រំ យុវជន នឹង កីឡា
- ធានាអោយបាននូវសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម
- ធ្វើរបាយការណ៍រាល់សកម្មភាពសិក្សា និងការគ្រប់គ្រងការងារបណ្តុះបណ្តាល ជូននាយកដ្ឋានឧត្តមសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា អោយបានទៀងទាត់តាមការកំណត់ ។

**មាត្រា ៨ :** និស្សិត ដែលរៀនចប់កម្មវិធីសិក្សា របស់សាកលវិទ្យាល័យអង្គរ និងទទួលបានជោគជ័យក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាប័ត្រ តាមកំរិត និង តាមឯកទេស ដែលបានសិក្សា។ សញ្ញាប័ត្រនេះ ផ្តល់អោយដោយសាកលវិទ្យាល័យអង្គរ ហើយត្រូវបាន ទទួលស្គាល់ ពីក្រសួងអប់រំ យុវជន និង កីឡា ក្នុងករណីសាកលវិទ្យាល័យ បានបំពេញ និង អនុវត្ត តាមគោលការណ៍ និង បទដ្ឋាន របស់ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៩ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា អភិបាលខេត្តសៀមរាប អគ្គនាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និង សាកលវិទ្យាល័យអង្គរ ត្រូវទទួលបន្ទុកអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
-សាលាខេត្តសៀមរាប

"ដើម្បីមុខការ"

-ដូចមាត្រា ៩ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ